*រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៩៣ អនក្រ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណា ព្រះបាទសម្តេចនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- យោងសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ :** តែងតាំង លោក **ឃ្លោក ប៊ុកឌី** ជានាយកខុទ្ទកាល័យ នៃក្រសួងមហាផ្ទៃ

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នពាក់ពន្ធ័និងលោក **ឃ្លោក ប៊ុកឌី** ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៩៤*

## សេចក្តីសំរេចលេខ ៩១ សសរ
## ស្តីពីការបង្កើតគណៈកម្មការចម្រុះ ស្រាវជ្រាវ ត្រួតពិនិត្យការបំផ្លិចបំផ្លាញ ប្រាសាទបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្ត បន្ទាយមានជ័យ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល

-យោងតាមសំណូមពរចាំបាច់នៃការងារ

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មការចំរុះស្រាវជ្រាវត្រួតពិនិត្យការបំផ្លិចបំផ្លាញប្រាសាទបន្ទាយឆ្មារ នៅស្រុកថ្មពួក ខេត្តបន្ទាយមាន ជ័យ ដែលសមាសភាពដូចតទៅ:

១- ឯកឧត្តម **នុត ណារ៉ាង** រដ្ឋលេខាធិការក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ ប្រធាន

២- លោកឧត្តមសេនីយឯក **ទែសន ចំរុង** តំណាងក្រសួងការពារជាតិ អនុប្រធាន

៣- លោកឧត្តមសេនីយទោ **គៅ លិមមី** តំណាងក្រសួងមហាផ្ទៃ អនុប្រធាន

៤- ឯកឧត្តម **ដួង ខែម** អភិបាលខេត្ត បន្ទាយមានជ័យ សមាជិក អចិន្ត្រៃយ៍

**ប្រការ ២** : គណៈកម្មការចំរុះនេះ មានភារកិច្ចដូចតទៅ:

- ជំនួយការអោយរាជរដ្ឋាភិបាលក្នុងការចុះទៅស្រាវជ្រាវត្រួតពិនិត្យជាក់ស្តែងនៅប្រាសាទបន្ទាយឆ្មារ
- ធ្វើការស្រាវជ្រាវអង្កេត និងប្រមូលយកគ្រប់ភស្តុតាងក្នុងការបំផ្លិចបំផ្លាញប្រាសាទនិងកសាងសំណុំរឿងចាំបាច់ ផ្សេងៗ ។
- ធ្វើរបាយការណ៍បូកសរុបវាយតំលៃការខូចខាតអោយបានច្បាស់លាស់ ដោយលើកវិធានការផ្សេងៗ ជូនរដ្ឋាភិ បាលដើម្បីចាត់ការជាបន្ទាន់ ។

**ប្រការ ៣** : សមាជិកទាំងអស់ នៃគណៈកម្មការនេះត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាននិងមានសិទ្ធិប្រើប្រាស់ មន្ត្រីរាជការនាយទាហាន នាយនគរបាល ក្រោមឱវាទសំរាប់ជំនួយការបន្ថែមក្នុងការងារនេះ ។

**ប្រការ ៤** : គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ ៥** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងអភិបាល ខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះចាប់ តាំងពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

*រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤*

## សេចក្តីសំរេចលេខ ៩២ សសរ

## ស្តីពីការផ្ទេរសិទ្ធិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**ប្រការ ១ :** ក្នុងឱកាសដែលឯកឧត្តម **ចាវ ហ្វុក** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅប្រទេសម៉ាឡេស៊ី ចាប់ពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤ នេះទៅការងារប្រចាំថ្ងៃរបស់ក្រសួងពាណិជ្ជកម្មត្រូវបានផ្ទេរជូនឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រីជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មស្តីទីជំនួសរហូតដល់ឯកឧត្តម **ចាវ ហ្វុក** អញ្ជើញត្រឡប់មកវិញ ។

**ប្រការ ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តមដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃឡាយព្រះហស្ត លេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

***